# I ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ អនុក្រឹត្យ

ភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៣

## អនុក្រឹត្យលេខ ០៧ អនក្រ
## ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ
## ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ

* * * * * *

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញសេចក្តីសំរេចចិត្ត នៃសភាធម្មនុញ្ញ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៣
- បានឃើញក្រឹត្យរបស់ សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ

## សំរេច

**មាត្រា ១** : ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ជាស្ថាប័នចំណុះរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា មានសមត្ថកិច្ចគ្រប់គ្រង ខេត្ត ក្រុង លើវិស័យរដ្ឋបាល គ្រប់គ្រងនគរបាលជាតិកម្ពុជា និង ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និង សុវត្ថិភាពជូនប្រជារាស្ត្រ ។

**មាត្រា ២** : ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ មានភារកិច្ចនិងសិទ្ធិដូចតទៅ ÷

- គ្រប់គ្រងខេត្ត-ក្រុង និង មន្ត្រីរាជការ ក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ។
- គ្រប់គ្រងខេត្ត-ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ តាមការកំណត់របស់ច្បាប់ ។
- រៀបចំតួនាទី ភារកិច្ច សិទ្ធិ និង អង្គការលេខរបស់ខេត្ត-ក្រុង ។
- តាមដានត្រួតពិនិត្យសកម្មភាពការងាររបស់ថ្នាក់ខេត្ត-ក្រុង ស្រុក ខ័ណ្ឌ ។

- ទទួលពាក្យបណ្ដឹងតវ៉ារបស់ប្រជារាស្ត្រនិងដោះស្រាយតាមសមត្ថកិច្ចដែលច្បាប់ប្រគល់អោយហើយដែលមានការពាក់ព័ន្ធដល់ការងាររបស់ថ្នាក់ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ។
- ដឹកនាំអនុវត្តការងារគ្រប់គ្រងផែនការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ខេត្ត ក្រុង និង ជំរុញការងារ រៀបចំកែទម្រង់ជីវភាពរស់នៅខាងស្មារតី សំភារៈ និងវប្បធម៌ ជូនប្រជារាស្ត្រ ។
- សហការជាមួយក្រសួងពាក់ព័ន្ធ ក្នុងការរៀបចំទីតាំង ភូមិដ្ឋានរបស់ប្រជារាស្ត្រ អោយស្របទៅតាមលក្ខណៈភូមិសាស្ត្រ ទំនៀមទំលាប់ ប្រពៃណី សាសនារបស់ប្រជារាស្ត្រ ។
- គ្រប់គ្រងពន្ធនាគារ ។
- ការពារអាយុជីវិត សិទ្ធិ សេរីភាព កិត្តិយស សេចក្ដីថ្លៃថ្នូរ ទ្រព្យសម្បត្តិ និង ផលប្រយោជន៍ស្របច្បាប់របស់ប្រជារាស្ត្រ ។
- ការពារសុវត្ថិភាពថ្នាក់ដឹកនាំជាតិ និង អន្តរជាតិ ។
- ការពារការសម្ងាត់ជាតិ ។
- ការពារស្ថាប័នជាតិ ។
- ការពារទ្រព្យសម្បត្តិសាធារណៈ ។
- ការពារស្ថាប័នទូត អង្គការអន្តរជាតិនានា គណៈប្រតិភូអន្តរជាតិ និង ជនបរទេសដែលស្នាក់នៅកម្ពុជា ។
- ការពារសម្បត្តិវប្បធម៌ និង បេតិកភ័ណ្ឌជាតិ ។
- ការពារសន្តិសុខសណ្ដាប់ធ្នាប់តាមបណ្ដោយព្រំដែន ។
- គ្រប់គ្រងការចុះបញ្ជីស្ថិតិប្រជារាស្ត្រជនបរទេសមុខរបរការផ្ដល់អត្តសញ្ញាណប័ណ្ណពលរដ្ឋប័ណ្ណសំគាល់ខ្លួន ជនអន្តោប្រវេសន៍ និង ការផ្ដល់លិខិតឆ្លងដែនពលរដ្ឋ ។
- ធ្វើបញ្ជីពលរដ្ឋ មានសិទ្ធិបោះឆ្នោត និង រៀបចំការបោះឆ្នោតផ្សេង ១ តាមច្បាប់ ។
- បូកសរុបលើគ្រប់វិស័យការងាររបស់ខេត្ត ក្រុង ។
- គ្រប់គ្រងសណ្ដាប់ធ្នាប់សាធារណៈ និង ចរាចរ ផ្លូវគោក ផ្លូវទឹក ។
- គ្រប់គ្រងការងារ បង្ការ និង ពន្លត់អគ្គិភ័យ ។
- គ្រប់គ្រងមន្ទីរពេទ្យ គិលានដ្ឋានរបស់នគរបាល ។
- គ្រប់គ្រងការប្រើប្រាស់វិទ្យុទាក់ទង ផ្នែកនគរបាល និង ស៊ីវិល ។
- គ្រប់គ្រងការងារអក្សរសម្ងាត់ ។
- គ្រប់គ្រងនិងត្រួតពិនិត្យ ការប្រើប្រាស់ ការដឹកនាំអាវុធ គ្រឿងផ្ទុះ ជាតិពុល និង ផ្ដល់លិខិតអនុញ្ញាតប្រើប្រាស់អាវុធផ្នែកស៊ីវិល ។

- បង្ការ និង បង្ក្រាបបទល្មើសព្រហ្មទណ្ឌ គ្រឿងញៀន អំពើភេរវកម្ម បទល្មើសសេដ្ឋកិច្ច និង បទល្មើសប្រឆាំង នឹងសន្តិសុខ ផ្សេង ក្នុងប្រទេសផ្សេង ៗ ។

- បង្ការ និង បង្ក្រាបអំពើពាលអនាធិបតេយ្យ និងអំពើល្មើសផ្សេង ៗ ទៀត ។

- ស៊ើបអង្កេតស្រាវជ្រាវបទល្មើសគ្រប់ប្រភេទ ចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួនបណ្តោះអាសន្នកសាងសំណុំរឿង និងបញ្ជូនសំណុំរឿងជនល្មើស ព្រមទាំងវត្ថុតាងទៅអយ្យការគ្រប់ថ្នាក់ ។

- អនុវត្ត និង សហការអនុវត្ត សាលក្រម ផ្តន្ទាទោសដាក់ពន្ធនាគារ ដីកា និង សេចក្តីសំរេចរបស់តុលាការ និង អយ្យការគ្រប់ថ្នាក់ ។

- គ្រប់គ្រងប៉ុស្តិ៍នគរបាល រដ្ឋបាល ។

- គ្រប់គ្រងប៉ុស្តិ៍នគរបាលព្រំដែនគោក ទឹក និង ព្រំដែនសមុទ្រ ។

- គ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់នៅច្រកទ្វារព្រំដែនគោក ទឹក សមុទ្រ និង អាកាស ។

- ហ្វឹកហ្វឺនបណ្តុះបណ្តាល និង វិក្រឹតការ មុខជំនាញនគរបាល និង ច្បាប់ អោយដល់នគរបាលជាតិកម្ពុជាគ្រប់ថ្នាក់ ។

- គ្រប់គ្រងចលនវត្ថុ និង អចលនវត្ថុរបស់ក្រសួង ។

- គ្រប់គ្រងហិរញ្ញវត្ថុ ភស្តុភារ មធ្យោបាយ សម្ភារៈឧបករណ៍ បច្ចេកទេស និងសំណង់របស់នគរបាលជាតិកម្ពុជា ។

- ទទួលពាក្យ និង ដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហាររបស់ប្រជារាស្ត្រដែលមានការពាក់ព័ន្ធដល់កិច្ចការនគរបាលជាតិ ។

- ស្រាវជ្រាវរកមនុស្សបាត់ខ្លួន

- សំណូមពរអោយក្រសួង ស្ថាប័ន អង្គការសង្គម និង ប្រជារាស្ត្រចូលរួមសហការក្នុងការបំពេញការកិច្ចចាំបាច់របស់ខ្លួន ។

- បង្គាប់អភិបាលខេត្ត ក្រុងអោយរាយការណ៍តាមការកំណត់ និងសំណូមពរអោយក្រសួងនិងស្ថាប័ននានាផ្តល់ជាបន្ទាន់ នូវពត៌មាន និង ឯកសារដែលមានការពាក់ព័ន្ធដល់សន្តិសុខជាតិ ។ ក្នុងករណីពិសេសអាចស្នើសុំតំណាងស្ថាប័នរដ្ឋដែលមានការពាក់ព័ន្ធអោយចូលរួមសហការ បំពេញការកិច្ចជាមួយនគរបាល ជាតិកម្ពុជា ។

- ផ្អាកជាបណ្តោះអាសន្នសេចក្តីសំរេចរបស់អភិបាលខេត្ត ក្រុង ក្នុងករណីមានការប្តឹងជំទាស់ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញ ។

- ចេញបញ្ជា និង ចាត់វិធានការជាបន្ទាន់ ដើម្បីបង្ការ និង បង្ក្រាបនូវរាល់សកម្មភាពដែលបង្កនូវគ្រោះមហន្តរាយដល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងជីវភាពរស់នៅរបស់ប្រជារាស្ត្រ ។

- អនុវត្តភារកិច្ច និង សិទ្ធិផ្សេងៗ ទៀត ដែលរដ្ឋាភិបាលជាតិនៃកម្ពុជាប្រគល់អោយ ។

មាត្រា ៣ : នគរបាលជាតិកម្ពុជា ដែលចុះទៅបំពេញ បេសកកម្មមានអាទិភាពក្នុងការធ្វើដំណើរ ទៅមកតាមមធ្យោបាយ គមនាគមន៍ សាធារណៈ ។ ក្នុងករណីពិសេសបន្ទាន់ ( បង្ក្រាបបទឧក្រិដ្ឋកម្ម ឬ ជួយសង្គ្រោះបន្ទាន់ ) នគរបាលជាតិ មានសិទ្ធិប្រើប្រាស់មធ្យោបាយ ទូរគមនាគមន៍និងមធ្យោបាយ បច្ចេកទេស ផ្សេងៗ ទៀត របស់អង្គការរដ្ឋ អង្គការសង្គម ។ ក្នុងករណីនេះឯកជនត្រូវចូលរួមសហការជាមួយនគរបាលមានសមត្ថកិច្ច ។

មាត្រា ៤ : ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ដឹកនាំដោយរដ្ឋមន្ត្រី មួយរូប អនុរដ្ឋមន្ត្រីជាជំនួយការ ។

មាត្រា ៥ : ទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ មានរចនាសម្ព័ន្ធដូចតទៅ :

- ខុទ្ទកាល័យ
- អគ្គាធិការដ្ឋាន កិច្ចការនយោបាយ រដ្ឋបាល និង នគរបាល
- អគ្គនាយកដ្ឋានមហាផ្ទៃ
- អគ្គនាយកដ្ឋាន នគរបាលជាតិ

ក - អគ្គនាយកដ្ឋានមហាផ្ទៃ មាន ៤ នាយកដ្ឋាន :

១- នាយកដ្ឋាន រដ្ឋបាលទូទៅ និង គ្រប់គ្រងខេត្ត ក្រុង

២- នាយកដ្ឋាន កិច្ចការនយោបាយ

៣- នាយកដ្ឋាន បុគ្គលិក និង បណ្តុះបណ្តាលវិជ្ជាជីវៈ

៤- នាយកដ្ឋាន ពន្ធនាគារ

ខ - អគ្គនាយកដ្ឋាន នគរបាលជាតិមាន :

- សេនាធិការដ្ឋាន
- ការិយាល័យ នគរបាលអន្តរជាតិ
- នាយកដ្ឋាន កណ្តាលប្រាំ

I - នាយកដ្ឋាន កណ្តាល នគរបាលព្រំដែនមាន ៣ នាយកដ្ឋាន :

១- នាយកដ្ឋាន នគរបាលព្រំដែនគោក

២- នាយកដ្ឋាន នគរបាលព្រំដែនទឹក

៣- នាយកដ្ឋាន បច្ចេកទេសព្រំដែន

II - នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់ សាធារណៈ មាន ៤ នាយកដ្ឋាន :

១- នាយកដ្ឋាន សណ្ដាប់ធ្នាប់សង្គម

២- នាយកដ្ឋាន នគរបាលការពារ

៣- នាយកដ្ឋាន នគរបាលរដ្ឋបាល

៤- នាយកដ្ឋាន ផ្សព្វផ្សាយអប់រំ

III - នាយកដ្ឋាន កណ្ដាល នគរបាលយុត្តិធម៌មាន ៤ នាយកដ្ឋាន :

១- នាយកដ្ឋាន នគរបាលព្រហ្មទណ្ឌ

២- នាយកដ្ឋាននគរបាលសេដ្ឋកិច្ច

៣- នាយកដ្ឋានបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

៤- នាយកដ្ឋាន និតិកម្ម

IV- នាយកដ្ឋានកណ្ដាល សន្តិសុខមាន បួន នាយកដ្ឋាន

១- នាយកដ្ឋានពត៌មានទូទៅ

២- នាយកដ្ឋានប្រឆាំងភេរវកម្ម

៣- នាយកដ្ឋាន អន្តោប្រវេសន៍

៤- នាយកដ្ឋាន អង្គរក្ស

V- នាយកដ្ឋាន កណ្ដាលបម្រើរដ្ឋបាលមាន ប្រាំ នាយកដ្ឋាន

១- នាយកដ្ឋានបុគ្គលិក

២- នាយកដ្ឋាន បណ្តុះបណ្តាល និងវិក្រឹតការ

៣- នាយកដ្ឋាន ភស្តុភារ និង សំភារៈបច្ចេកទេស

៤- នាយកដ្ឋានស្ថាបនា និង ជួសជុល

៥- នាយកដ្ឋាន សុខាភិបាល

ខុទ្ទកាល័យ អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋានកណ្ដាល នាយកដ្ឋានសេនាធិការដ្ឋាន ក...
ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានពីររូប ។

មាត្រា ៦ : ចំពោះនាយកដ្ឋានផែនការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នាយកដ្ឋានវិទ្យុទាក់ទង និង នាយកដ្ឋានអក្សរ...
ស្ថិតនៅក្រោមការត្រួតត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានមហាផ្ទៃ និង អគ្គនាយកដ្ឋាននគរបាលជាតិ និង ...
កិច្ចបំពេញការងារតាមមុខងារ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អគ្គនាយកដ្ឋាននីមួយៗ មានដំណើរការប្រ...
បានល្អ ។

**មាត្រា ៧** ៖ រចនាសម្ព័ន្ធចាត់តាំង នគរបាលជាតិកម្ពុជានៅមូលដ្ឋានរួមមាន ៖

- ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ។
- អធិការដ្ឋាននគរបាលស្រុក ខណ្ឌ ។
- ប៉ុស្តិ៍នគរបាលរដ្ឋបាល ។

ស្នងការដ្ឋាន អធិការដ្ឋាន ប៉ុស្តិ៍នគរបាលរដ្ឋបាលដឹកនាំដោយប្រធានមួយរូប និង អនុប្រធាន ជំនួយការ ។

**មាត្រា ៨** ៖ ការរៀបចំតួនាទីភារកិច្ច សិទ្ធិ និង រចនាសម្ព័ន្ធរបស់ ខុទ្ទកាល័យអគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយក កណ្តាលនាយកដ្ឋានសេនាធិការដ្ឋានការិយាល័យស្នងការដ្ឋាននិងប៉ុស្តិ៍ត្រូវកំណត់ដោយ ប្រកាសរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ។

**មាត្រា ៩** ៖ ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ អាចចេញប្រកាសរួមក្នុងនាមអន្តរក្រសួង លើករណីដែលមាន ការទាក់ទងដល់តួនាទីភារកិច្ចសិទ្ធិអំណាចរបស់ខ្លួនជាមួយក្រសួង ស្ថាប័នផ្សេង ៗ ទៀត ។

**មាត្រា ១០** ៖ ក្របខ័ណ្ឌ មន្ត្រី រដ្ឋការ បុគ្គលិកនគរបាលជាតិ និង ទីប្រឹក្សារបស់ក្រសួងមហាផ្ទៃនិង សន្តិសុខជាតិ ត្រូវកំណត់ដោយរដ្ឋាភិបាល ។

**មាត្រា ១១** ៖ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹង អនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១២** ៖ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សន្តិសុខជាតិរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុរដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានស្ថាប័នដែលមានការពាក់ព័ន្ធនិង អភិបាលគ្រប់ខេត្តក្រុងត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

ព្រះហស្តលេខា        ហត្ថលេខា និង ត្រា

ស្តេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ**        **ហ៊ុន សែន**

****


រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ
អ នុ រ ដ្ឋ ម ន្ត្រី
អគ្គាធិការកិច្ចការ នយោបាយ-រដ្ឋបាល-នគរបាល
អ គ្គ នា យ ក ម ហា ផ្ទៃ
ខុ ទ្ទ កា ល័ យ
កាំ.ប៉ូលិសអន្តរជាតិ
អគ្គនាយក នគរបាលជាតិ
សេនាធិការដ្ឋាន
នាយក រដ្ឋបាលទូទៅ-គ្រប់គ្រងខេត្ត ក្រុង
នាយក កិច្ចការ នយោបាយ
នាយ ក ពន្ធនាគារ
ន.យ.ផែនការ-សេដ្ឋកិច្ច-ហិរញ្ញវត្ថុ
ន.យ.វិទ្យុទាក់ទង
ន.យ.អក្សរសម្ងាត់
ន.យ. កណ្តាល ន.ប. ព្រំដែន
ន.យ.កណ្តាល សណ្តាប់ធ្នាប់សាធារណៈ
ន.យ. កណ្តាល ន.ប. យុត្តិធម៌
ន.យ. កណ្តាល សន្តិសុខ
ន.យ. កណ្តាល មធ្យោបាយ
ន.យ. បុគ្គលិក
ន.យ. បណ្តុះបណ្តាលនិងវិក្រឹតការ
ន.យ. ភស្តុភារ សំភារៈបច្ចេកទេស
ន.យ. ស្ថាបនា និង ផ្គត់ផ្គង់
ន.យ. សុខាភិបាល
ន.យ. សណ្តាប់ធ្នាប់សង្គម
ន.យ. ន.ប. ការពារ
ន.យ. ន.ប. រដ្ឋបាល
ន.យ. ផ្សព្វផ្សាយអប់រំ
ន.យ. ន.ប ព្រហ្មទណ្ឌ
ន.យ ន.ប. សេដ្ឋកិច្ច
ន.យ. បច្ចេកទេសនិងវិទ្យាសាស្ត្រព្រហ្មទណ្ឌ
ន.យ. និតិកម្ម
ន.យ. ពត៌មានទូទៅ
ន.យ. ភេរវកម្ម
ន.យ. អន្តោប្រវេសន៍
ន.យ. អង្គរក្ស
ន.ប. ព្រំដែនគោក
ន.ប. ព្រំដែនទឹក
ន.យ. បច្ចេកទេសព្រំដែន
ស្នងការដ្ឋាន ន.ប. ខេត្ត ក្រុង
អធិការដ្ឋាន ន.ប. ខណ្ឌ ស្រុក
ប៉ុស្តិ៍ ន.ប. រដ្ឋបាល